**គណៈកម្មាធិការរៀបចំ**
**Organizing Committee**

# សេចក្ដីប្រកាសព័ត៌មាន

## គណបក្សនយោបាយធំៗបង្ហាញគោលនយោបាយបោះឆ្នោត

**រាជធានីភ្នំពេញ ថ្ងៃទី៦ ខែមិថុនា៖** ថ្ងៃនេះ តំណាងសហគមន៍ សង្គមស៊ីវិល និងគណបក្សនយោបាយ ចំនួន ៣៥០នាក់ បានជួបជុំគ្នាដើម្បីស្ដាប់តំណាងគណបក្សនយោបាយធំៗបង្ហាញអំពីគោលនយោបាយរបស់ខ្លួន នៅក្នុងអំឡុងពេលឈានដល់ការបោះឆ្នោតជាតិនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣។

រៀបចំដោយអង្គការមិនមែនរដ្ឋាភិបាលមួយក្រុម វេទិកានយោបាយនេះសំដៅផ្ដល់ឱកាសឲ្យប្រជាពលរដ្ឋបានស្ដាប់គោលនយោបាយរបស់គណបក្សនយោបាយសំខាន់ៗ ដែលឈរឈ្មោះក្នុងការបោះឆ្នោតនាពេលខាងមុខនេះ។

គណបក្សនយោបាយទាំងនោះ ដែលបានបង្ហាញគោលនយោបាយក្នុងវេទិកានេះរួមមាន គណបក្សសង្គ្រោះជាតិ (CNRP) និងគណបក្សហ៊្វុនស៊ិនប៉ិច។ គណបក្សប្រជាជនកម្ពុជា(CPP) បានបដិសេធមិនចូលរួម។

បេក្ខជនគណបក្សត្រូវបានស្នើឲ្យបង្ហាញគោលនយោបាយរបស់ខ្លួនក្រោមប្រធានបទសំខាន់ៗចំនួនបួន គឺ (១)**កំណែទម្រង់សេដ្ឋកិច្ច និងដីធ្លី** (២)**បរិស្ថានព្រៃឈើ និងបម្រែបម្រួលអាកាសធាតុ** (៣)**ការអភិវឌ្ឍសង្គម និងមនុស្ស និង** (៤)**នីតិរដ្ឋ អភិបាលកិច្ចល្អ និងការទទួលព័ត៌មាន។**

"វាគឺជាគោលការណ៍គ្រឹះនៃសង្គមប្រជាធិបតេយ្យមួយ ដែលប្រជាពលរដ្ឋមានសិទ្ធិដឹងលឺនូវគោលនយោបាយទាំងឡាយដែលគណបក្សនយោបាយនឹងពាំនាំទៅកាន់ការបោះឆ្នោត" លោក ឈិត សំអាត នាយកប្រតិបត្តិនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជាបានមានប្រសាសន៍។

លោកបានបន្តទៀតថា "យើងដំណើរការវេទិកានាថ្ងៃនេះ ដើម្បីឲ្យប្រជាពលរដ្ឋអាចស្ដាប់គោលនយោបាយរបស់គណបក្សនយោបាយ និងលើកឡើងនូវសំណួរអំពីបញ្ហាដែលជាក្ដីបារម្ភរបស់ពួកគេ។ យើងសង្ឃឹមថា វេទិកានេះនឹងជួយធានាឲ្យបានថា ប្រជាជនកម្ពុជាបានទទួលព័ត៌មានកាន់តែច្រើន នៅពេលដែលពួកគេត្រៀមខ្លួនធ្វើការជ្រើសរើសអ្នកដែលពួកគេនឹងបោះឆ្នោតសម្រាប់រាជរដ្ឋាភិបាលអណ្ដត្តិក្រោយនេះ"។

ក្រោមប្រធានបទនីមួយៗ សំណួរមួយចំនួន បានបង្ហាញយ៉ាងពេញលេញនូវបញ្ហាធំៗដែលប្រជាជនកម្ពុជាជួបប្រទះនាពេលបច្ចុប្បន្ន។

ក្រោមប្រធានបទ**កំណែទម្រង់សេដ្ឋកិច្ច និងដីធ្លី** បេក្ខជនម្នាក់ៗត្រូវបានសួរពីគោលនយោបាយដែលពួកគេនឹងធានាឲ្យបាននូវគណនេយ្យភាព និងតម្លាភាពក្នុងការគ្រប់គ្រងថវិកាជាតិ និងចំណូលពីឧស្សាហកម្មនិស្សារណកម្ម ក៏ដូចជាការជំរុញការអភិវឌ្ឍសេវាសាធារណៈប្រកបដោយសមធម៌ ដើម្បីបំពេញសេចក្ដីត្រូវការរបស់បុរសនិងស្ត្រី ព្រមទាំងធានាឲ្យបាននូវការចូលរួមជាសាធារណៈនៅក្នុងកិច្ចដំណើរការរៀបចំផែនការជាតិ។

**គណៈកម្មាធិការរៀបចំ**
**Organizing Committee**

ទាក់ទិននឹងប្រធានបទ **បរិស្ថាន ការគ្រប់គ្រងព្រៃឈើ និងបម្រែបម្រួលអាកាសធាតុ** បេក្ខជនត្រូវបានសួរអំពីគោលនយោបាយដែលគណបក្សធ្វើការបញ្ជ្រាបគោលនយោបាយស្តីពីបម្រែបម្រួលអាកាសធាតុ ការគ្រប់គ្រងបញ្ហាឆ្លងព្រំដែន ដូចជាការអភិវឌ្ឍវារីអគ្គិសនី ជាដើម ការធានាឲ្យបានថា ប្រទេសកម្ពុជានឹងទទួលបានផលប្រយោជន៍ពីទីផ្សារកាបោន និងធានាឲ្យបាននូវការទទួលព័ត៌មានស្តីពីបញ្ហាទាំងអស់នេះសម្រាប់បុរស និងស្ត្រី។

ក្រោមប្រធានបទ**អភិវឌ្ឍន៍សង្គម និងមនុស្ស** បេក្ខជនបានលើកឡើងពីគោលនយោបាយរបស់ខ្លួនស្តីពីបញ្ហាជាអាទិភាពសម្រាប់ការអភិវឌ្ឍសង្គមនៅកម្ពុជា គោលនយោបាយដែលធានាឲ្យបាននូវគុណភាពនៃការអប់រំ និងសេវាសុខភាពនៅកម្ពុជា ក៏ដូចជាថាតើពួកគេនឹងដាក់ឲ្យអនុវត្តប្រព័ន្ធសុវត្ថិភាពសង្គមឬទេ និងធានាឲ្យបានថាប្រជាជនកម្ពុជាទាំងអស់អាចទទួលបានសេវាទាំងនេះដោយស្មើភាពគ្នា។

នៅក្នុងវគ្គចុងក្រោយស្តីពី**នីតិរដ្ឋ អភិបាលកិច្ចល្អនិង ការទទួលព័ត៌មាន** បេក្ខជនត្រូវបានសួរអំពីរបៀបដែលពួកគេនឹងធានាឲ្យបានថា តុលាការគឺឯករាជ្យនិងមិនលំអៀង តើពួកគេនឹងប្រើយុទ្ធសាស្ត្រអ្វីខ្លះដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងរបៀបដែលពួកគេរៀបចំដើម្បីអនុម័តច្បាប់ស្តីពីការទទួលព័ត៌មាន។

វេទិកាបានទទួលការចូលរួមពីតំណាងសហគមន៍អង្គការសង្គមស៊ីវិល តំណាងគណបក្សនយោបាយ ដៃគូអភិវឌ្ឍន៍ និង សហគមន៍ការទូត។

**ចប់**

**ទំនាក់ទំនង៖ លោក ឈិត សំអាត វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា០១២ ៩២៨៥៨៥**
**លោក យុធ្យា ស៊ន់ អង្គការខុមហ្វ្រែល ០៨៨ ៨១៤២៧៨៣**